ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ: ..១៤.០៤..... PC.អក

# សេចក្តីជូនដំណឹង
## ស្តីពី

ការងារសាងសង់អគារការិយាល័យ ទំហំ (9 m x 18 m) មានជាន់ផ្ទាល់ដី និងជាន់ទី១, ចាក់ដីបំពេញបន្ថែមទំហំ 10,000 m$^2$ កំពស់ 0.2 m, សាងសង់របង 03 ជ្រុង ប្រវែង 297.40 m និងលាបថ្នាំរបងប្រវែង 104.28 m នៅសាខាត្បូងឃ្មុំ ក្នុងតំបន់រដ្ឋបាលសាលាខេត្តត្បូងឃ្មុំ របស់អគ្គិសនីកំពង់ចាម

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើស អ្នកទទួលការងារសាងសង់អគារការិយាល័យ ទំហំ (9 m x 18 m) មានជាន់ផ្ទាល់ដី និងជាន់ទី១, ចាក់ដីបំពេញបន្ថែមទំហំ 10,000 m$^2$ កំពស់ 0.2 m, សាងសង់របង 03 ជ្រុង ប្រវែង 297.40 m និងលាបថ្នាំរបងប្រវែង 104.28 m នៅសាខាត្បូងឃ្មុំ ក្នុងតំបន់រដ្ឋបាលសាលាខេត្តត្បូងឃ្មុំ របស់អគ្គិសនីកំពង់ចាម ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋាន អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពី ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 និង Website : www.edc.com.kh ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៨ វេលាម៉ោង ១៤:00 ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋាន ខាងលើវេលាម៉ោង ១៥:៣០ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ ចន្ទ ៩ រោច ខែ ចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៨
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ធីវ ធឿង

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ